# សេចក្ដីថ្លែងការណ៍របស់អ្នកស្រី ណាវី ភីឡៃ ឧត្តមស្នងការអ.ស.ប
# ទទួលបន្ទុកសិទ្ធិមនុស្សនៅក្នុងឱកាសខួបលើកទី៦០
# នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

" ១០ ធ្នូ គឺជាទិវារំលឹកខួបលើកទី៦០ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស វាជាឯកសារខ្លីមួយដែលមាន៣០ មាត្រាដែលប្រហែលជាមានឥទ្ធិពលទៅលើមនុស្សជាតិច្រើនជាងឯកសារឯទៀតក្នុងប្រវត្តិសាស្ត្រថ្មី។

ភ្លាមៗក្រោយពីចប់សង្គ្រាមលោកលើកទីពីរ អ្នកនយោបាយពិភពលោក អ្នកការទូត អ្នកសារព័ត៌មាន សកម្មជន អ្នកគិត និងជាពិសេស មនុស្សទូទៅលើពិភពលោកបានមានបំណងធ្វើការទប់ស្កាត់សង្គ្រាមនេះមិនឱ្យកើតមានជាថ្មី ក្នុងន័យដោះស្រាយបុព្វហេតុនៃសង្គ្រាម និងវិបាកនៅក្រោយសង្គ្រាម។ ពួកគេបានប្ដេជ្ញាចិត្តដើម្បីធានាថានឹងមិនឱ្យហាយនភាពមួយទៀតកើតមានឡើយ ហើយថាមនុស្សគ្រប់រូប ជាពិសេសទុគ៌តជន អ្នកអត់ឃ្លាន ជនចំណាក់ស្រុក និងអ្នកដែលគេមិនសូវគិតគូរ - នៅថ្ងៃអានាគតមានប្រព័ន្ធដែលគាំទ្រដល់ពួកគេ និងមានក្របខ័ណ្ឌច្បាប់អន្តរជាតិដើម្បីការពារពួកគេ។

ភាគច្រើននៃស្ថាប័ន និងសន្ធិសញ្ញាសំខាន់ៗបំផុតនៃពិភពលោក រួមមានអង្គការសហប្រជាជាតិផ្ទាល់គិតចាប់ពីសម័យរុងរឿងនៅចុងទសវត្សរ៍ឆ្នាំ១៩៤០មក ប៉ុន្តែសេចក្ដីប្រកាសជាសកលស្ថិតក្នុងទីតាំងមួយដែលពិសេសបំផុត។

ដំបូងគេបង្ហាស់ សិទ្ធិមនុស្សមាន សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលត្រូវបានទទួលស្គាល់ថាជាសិទ្ធិដែលមានជាប់ពីកំណើតរបស់មនុស្សទាំងអស់ ជាជាងអ្វីដែលគេផ្ដល់ឱ្យពួកគេជាអំណោយសប្បុរសធម៌ ឬបដិសេធមិនផ្ដល់ឱ្យពួកគេ តាមរយៈការតាក់តែង ជោគវាសនា ឬគំនិតស្រមើលស្រមៃនៃរបបគ្រប់គ្រងណាមួយ។

វាមិនត្រឹមតែជាគំនិតហួសវិស័យប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាគោលការណ៍គ្រឹះដែលស្ដែងឡើងតាមពាក្យពេចន៍ដែលល្អបំផុតថា : " មនុស្សទាំងអស់កើតមកមានសេរីភាពនិងសមភាពក្នុងផ្នែកសេចក្ដីថ្លៃថ្នូរ និងសិទ្ធិ.....។ បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ "។ ម្យ៉ាងទៀត សេចក្ដីប្រកាសនេះបង្កើតបញ្ជីសិទ្ធិមួយចំនួន រាប់ពីសិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម សិទ្ធិមិនត្រូវបានគេយកធ្វើជាទាសករ ឬសិទ្ធិមិនត្រូវបានគេឃុំឃាំងតាមទំនើងចិត្ត តាមរយៈ

សិទ្ធិសេរីភាពក្នុងការសំដែងមតិយោបល់ និងសិទ្ធិប្រតិបត្តិសាសនា រហូតដល់សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដូចជាការអប់រំ សុខភាព និងការទទួលប្រាក់ឈ្នួលស្មើគ្នាចំពោះការងារមានតម្លៃស្មើគ្នា។

សេចក្តីប្រកាសនេះចែងថាមនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស " ដោយគ្មានការប្រកាន់បែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយឬមតិផ្សេងៗទៀត...." ។

បច្ចុប្បន្ននេះ គោលការណ៍ទាំងឡាយដែលមានចែងក្នុងសេចក្តីប្រកាសជាសកលនេះត្រូវបានប្រទេសច្រើនជាង៩០ ដាក់បញ្ចូលទៅក្នុងច្បាប់ និងរដ្ឋធម្មនុញ្ញរបស់ខ្លួន។ យន្តការជាតិ តំបន់ និងអន្តរជាតិដែលលះបង់ដើម្បីការងារសិទ្ធិមនុស្ស រាប់ទាំងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងក្រុមប្រឹក្សាសិទ្ធិមនុស្សដែលមានអ្នកជំនាញការឯករាជ្យរបស់ខ្លួន ត្រូវបានបង្កើតឡើងដើម្បីឃ្លាំមើល លើកស្ទួយ ការពារ និងអភិវឌ្ឍសិទ្ធិមនុស្សថែមទៀត។

នៅទូទាំងពិភពលោក ចំនួនច្រើនសន្ធឹកសន្ធាប់នៃអ្នកសារព័ត៌មាន អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបានយកចិត្តទុកដាក់ខ្លាំងជាងមុន និងតាមឃ្លាំមើលជិតដល់ថែមទៀតទៅលើការអនុវត្តន៍សិទ្ធិមនុស្សរបស់រដ្ឋាភិបាលខ្លួន។ ការរីកចំរើននៃប្រព័ន្ធអ៊ីនធឺណែតបានធ្វើឱ្យអ្នកដែលចង់រំលោភសិទ្ធិប្រជាពលរដ្ឋខ្លួនដោយលាក់កំបាំងត្រូវជួបការលំបាកខ្លាំងឡើងថែមទៀតក្នុងការធ្វើដូច្នោះ ផ្ទុយទៅវិញអ្នកដែលចង់លាតត្រដាងអំពើរំលោភទាំងនោះ ពួកគេរិតតែមានភាពងាយស្រួលច្រើនជាងមុន។

ទោះជាយ៉ាងណាក៏ដោយ សំរាប់មនុស្សជាច្រើន សេចក្តីប្រកាសជាសកលនេះនៅតែជាការសន្យាមួយដែលមិនទាន់បានបំពេញនៅឡើយ ដោយសារតែឆន្ទះនយោបាយរបស់រដ្ឋក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនមានការយឺតយ៉ាវនៅពីក្រោយការសន្យារបស់ខ្លួន។

មានហានិភ័យជាក់ស្តែងមួយគឺ ដោយសារបច្ចុប្បន្នវិបត្តិហិរញ្ញវត្ថុនៅមិនទាន់បានដោះស្រាយ បុគ្គល និងសហគមន៍នានាដែលក្រីក្របំផុត និងដែលគេមិនសូវគិតគូរអាចនឹងប្រឈមមុខនឹងស្ថានការណ៍ធ្ងន់ធ្ងរជាងដែលពួកគេជួបប្រទះនាពេលបច្ចុប្បន្ននេះ។ ភាពក្រីក្រកើតចេញពីបុព្វហេតុ និងលទ្ធផលនៃការរំលោភសិទ្ធិមនុស្ស ហើយយើងត្រូវតែតាមឃ្លាំមើលខ្លាំងឡើងថែមទៀតនៅអំឡុងពេលជាច្រើនខែទៅមុខ ដើម្បីធានាឱ្យកម្មវិធីអភិវឌ្ឍ និងបណ្តាញសុវត្ថិភាពសង្គម ត្រូវបានរក្សាឬពង្រឹង ដូច្នេះឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុនឹងមិនអាចក្លាយទៅជាគ្រោះមហន្តរាយបានឡើយ។

ទោះជាបច្ចុប្បន្នមានភាពភ័យខ្លាច និងភាពមិនប្រាកដប្រជាក្តី ខ្ញុំមានសេចក្តីរីករាយដោយឃើញមានការយកចិត្តទុកដាក់ខ្លាំងអស្ចារ្យចំពោះការរំលឹកខួបរយៈពេលមួយឆ្នាំនៃខួបលើកទី៦០ ដែលផ្តោតទៅលើ

បញ្ហាសិទ្ធិមនុស្ស ។ នៅទូទាំងពិភពលោក អង្គការស្ម័គ្រចិត្ត ស្ថាប័ន គ្រូបង្រៀន សិស្សនិស្សិត អ្នកច្បាប់ អ្នកនយោបាយ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបានផ្តោតការយកចិត្តទុកដាក់លើសេចក្តីប្រកាសជាសកល និងការបន្តអនុវត្តសេចក្តីប្រកាសនេះនៅក្នុងពិភពលោកនាបច្ចុប្បន្ននេះ ។ ប៉ុន្តែយើងមិនអាចឈប់ត្រឹមនេះទេ ។ យើងនៅមានពេលមួយដ៏វែងឆ្ងាយបំផុត ( ៦០ ឆ្នាំទៅមុខ) ដើម្បីអនុវត្តឱ្យសំរេចគោលដៅទាំងឡាយដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលនេះ ។ គ្មានប្រទេសណាមួយនៅលើពិភពលោកនេះអាចអង្គុយនៅស្ងៀម ហើយនិយាយថា " យើងនឹងទៅដល់ទីនោះ " ឡើយ ។

មនុស្សរាប់សែនលាននាក់នៅជុំវិញពិភពលោកនៅមិនទាន់ដឹងថាខ្លួនមានសិទ្ធិដែលពួកគេអាចទាមទារបាន ហើយថារដ្ឋាភិបាលរបស់ខ្លួនត្រូវទទួលខុសត្រូវចំពោះពួកគេ និងចំពោះកន្សោមវិធានច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលផ្តោតសំខាន់លើសិទ្ធិជាមូលដ្ឋាន ។ ទោះបីជារាល់ការខិតខំប្រឹងប្រែងរបស់យើងរយៈពេល ៦០ ឆ្នាំកន្លងមកក្តី ក៏មានមនុស្សជាច្រើនមិនអើពើចំពោះខួបនេះដែរ ហើយការសំខាន់គឺយើងត្រូវបន្តកំលាំងជំរុញនេះតទៅទៀត ដើម្បីឱ្យមនុស្សច្រើនឡើងៗថែមទៀត អាចក្រោកឈរឡើងទាមទារសិទ្ធិរបស់ខ្លួន ។

ចំពោះហេតុផលនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះការដែលថាឆ្នាំក្រោយយើងបានគ្រោងឱ្យមានឆ្នាំអន្តរជាតិនៃការយល់ដឹងអំពីសិទ្ធិមនុស្ស ។ ហើយខ្ញុំសូមជំរុញលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន គ្រូបង្រៀន មាតាបិតា និងអ្នកឯទៀតដែលមានភារៈទទួលខុសត្រូវនៅទូទាំងពិភពលោក ឆ្លៀតយកឱកាសនេះដើម្បីធានាថាមនុស្សជំនាន់ក្រោយបានទទួលឱកាសច្រើនជាអតិបរមាដើម្បីទាមទារអ្វីដែលបានសន្យាផ្តល់ឱ្យពួកគេនៅក្នុងឯកសារវិសាមញ្ញនេះដែលគេស្គាល់ថា " សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស " ។

**ចប់**